*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២៥/៥៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ
នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩៤រូបៈ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ហេង សុភារិទ្ធ | ២- | លោក | គី រារិន |
| ៣- | លោក | សេង ម៉េង | | | |

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ង៉ែត ជាប៉ា | ២- | លោក | មោង ម៉ាន់ |
| ៣- | លោក | ជាន សុម៉ានី | ៤- | លោកស្រី | ទឹម គឹមលាង |
| ៥- | លោក | ប៉ែន សេដ្ឋា | ៦- | លោក | កាយ កាំងមាន |
| ៧- | លោកស្រី | សាខន សុផានី | ៨- | លោក | សន សុធី |
| ៩- | លោក | ប្រាក់ លាងហួរ | ១០- | លោក | លី ឡា |
| ១១- | លោក | អំ ចាន់បូរិត | ១២- | លោក | លិន សូពៅ |
| ១៣- | លោកស្រី | គាវ ដាវី | ១៤- | លោក | គា ផា |
| ១៥- | លោក | អ៊ុង សេរីវុឌ្ឍ | ១៦- | លោក | ឃន សារ៉េត |
| ១៧- | លោកស្រី | អ៊ួង អេង | ១៨- | លោក | សំ សំអាន |
| ១៩- | លោកស្រី | គិត សុខងឹម | ២០- | លោក | កើត គា |
| ២១- | លោក | ហ៊ឹម ប៊ុនថៃ | ២២- | លោកស្រី | សឹង សាលីនីន |
| ២៣- | លោក | ឈ ប៊ុនលី | ២៤- | លោក | អ៊ូច ឡង់ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | កើត កិត្តិនាថ | ២- | លោក | សុខ ប៉ុណ្ណៈកុសល |
| ៣- | លោក | នេ វិសិទ្ធិ | ៤- | លោក | សួង សូត្រ |

ឃ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ផៃ ពិទូ | ២- | លោក | ហេង ប៊ុននី |
| ៣- | លោក | ជា មករា | ៤- | លោក | ស៊ុន ទ្រី |
| ៥- | លោក | ឡឹក វ៉ាត្ន | ៦- | លោក | ឈឿន ពន្លឺ |
| ៧- | លោក | កុំ វិមល | ៨- | លោក | ម៉ែន វណ្ណៈ |
| ៩- | លោក | ហ៊ុន ស៊ីថា | ១០- | លោក | ឡា ពុទ្ធារី |
| ១១- | លោក | ប៉ក់ ដាលី | ១២- | លោក | ឡុង រត្តនៈកុមារ |
| ១៣- | លោក | សួយ សារិទ្ធ | ១៤- | លោកស្រី | ប្រាជ្ញ ច័ន្ទម៉ាលី |
| ១៥- | លោក | អ៊ុន បុញ្ញធារី | ១៦- | លោក | ព្រឿង សុឃៀង |
| ១៧- | លោក | ហៃ វាសនា | ១៨- | លោក | ឡាយ គិមលាង |
| ១៩- | លោក | ប៉ុក វីរៈ | ២០- | លោក | ខេង យ៉ាសិទ្ធ |
| ២១- | លោក | សេង ហៃ | ២២- | លោក | ឈឿង ផល្លី |
| ២៣- | លោក | តាក សីហាក់ | ២៤- | លោក | ជុំ ច័ន្ទតារា |
| ២៥- | លោកស្រី | បន វទ្ធា | ២៦- | លោក | អួន ស៊ីណាត |
| ២៧- | លោក | យឹម អូន | ២៨- | លោក | ចិន វិសាល |
| ២៩- | លោក | ទិត្យ ចាន់ | ៣០- | លោក | សិត សារិន |
| ៣១- | លោក | អោក ដារុណ | ៣២- | លោក | ស៊ិន សាវុទ្ធ |
| ៣៣- | លោក | ផុន ប៊ិច | ៣៤- | លោក | ជូ សារឹម |
| ៣៥- | លោក | អ៊ិន ហ៊ុល | ៣៦- | លោក | សេង លាង |
| ៣៧- | លោក | ស៊ុំ គង់ | ៣៨- | លោក | ហង់ សារិន |
| ៣៩- | លោក | ចាយ គង់គ្រុយ | | | |

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | អ៊ុច វុត្ថា | ២- | លោកស្រី | ហង់ ណារី |
| ៣- | លោកស្រី | គយ សុខុម | ៤- | លោកស្រី | ម៉ិល ច័ន្ទទេវី |
| ៥- | លោក | គង់ វិសាល | | | |

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | ងិន ឆាយ | ២- | លោក | ស្រ៊ុន លីមសុង |
| [illegible] | លោក | សុង ហុង | ៤- | លោកស្រី | ព្រុំ បុណ្ណមី |
| [illegible] | លោក | លី គួង | ៦- | លោក | ប៊ុនទួន ស៊ីមូណា |
| [illegible] | លោក | លឹម ងួនគ្រុយ | ៨- | លោក | ផា ឋាម |
| ៩- | លោក | ប៉ាង វណ្ណាសេដ្ឋ | ១០- | លោក | ហាស់ ពិសិទ្ធ |



ឆ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ឡាំ ខ័នណាឫទ្ធិ | ២- | លោក | ជី សុចិន្តា |
| ៣- | លោក | រុន សុផាន់ណារ៉ា | ៤- | លោក | ណុប សារិន |
| ៥- | លោក | ទ្រី សុកក្តិ | ៦- | លោកបណ្ឌិត | លាង សុផា |
| ៧- | លោក | កៅ មុនីរិទ្ធ | ៨- | លោកស្រី | ឌុច សុធារី |
| ៩- | លោកស្រី | ឈី សាវរី | | | |

នរោត្តម សីហមុនី

ពរល . ២៥០៤ . ៥៩១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ២៨ *ខែមេសា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិសុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៥/៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តាំងស៊ប់ដល់លោក **ហ៊ាង ច័ន្ទបូរី** ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥។

**មាត្រា២** : សម្តេចមហាបវរធិបតី ហ៊ុន **ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣រល. ២៥០៥.៦០៣

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានយកសេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើម

**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកស្តីការគណៈរដ្ឋមន្ត្រី**

**បណ្ឌិតសភាចារ្យ ហ៊ីខ ចូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៥/ ៦០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលយកសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសបង្គាប់

**មាត្រា១ :** តាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌ ដល់មន្ត្រីរាជការ ០៥ រូប ដែលបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤៖

| | | |
|---|---|---|
| ១-លោក **ឃឹម រតនៈ** | អនុមន្ត្រី | ថ្នាក់លេខ ១ |
| ២-លោក **ឈុង ដាវីន** | អនុមន្ត្រី | ថ្នាក់លេខ ១ |
| ៣-លោកស្រី **ម៉ុនថន ពេជ្របញ្ញាពណ៌** | អនុមន្ត្រី | ថ្នាក់លេខ ១ |
| ៤-លោក **ម៉ន សុខសីលា** | អនុមន្ត្រី | ថ្នាក់លេខ ១ |
| ៥-លោកស្រី **នី ហង្សា** | អនុមន្ត្រី | ថ្នាក់លេខ ១។ |

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា

ព្រះរាជក្រឹត្យ. ២៥០៥.៦០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

បានបង្ហាញត្រឹមត្រូវតាមច្បាប់ដើម
**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **ហ៊ុន ឋុវ៉ាក់ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់
# គណៈកម្មាធិការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ **គណៈកម្មាធិការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា** សរសេរជាអក្សរកាត់ថា **គ.ម.ហ.** ដែលជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជាក្នុងព្រះរាជាណាចក្រកម្ពុជា។

**គណៈកម្មាធិការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា** ( International Financial Center Committee of Cambodia ( IFCCC ) ) សំដៅដល់គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ និង **មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា** ( International Financial Center of Cambodia ( IFCC ) ) សំដៅដល់មណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ស្របតាមមាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០។

## ជំពូកទី២

## តួនាទី និងភារកិច្ចរបស់ គ.ម.ហ.

**មាត្រា២ .-**

**គ.ម.ហ.** មានតួនាទី និងភារកិច្ច ដូចតទៅ៖

- រៀបចំក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងវិធានការចាំបាច់នានា ក្នុងការសម្របសម្រួល ការគ្រប់គ្រង និងការត្រួតពិនិត្យមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- រៀបចំគោលនយោបាយលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ ក្នុងគោលបំណងទាក់ទាញវិនិយោគិនបរទេស
- រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់កិច្ចដំណើរការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- ជំរុញ និងពង្រឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ពិនិត្យ និងផ្តល់ការអនុម័តលើផែនការមេ ឬការស្នើសុំកែប្រែផែនការមេនៃគម្រោងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- ពិនិត្យ និងផ្តល់កាអនុម័តលើការស្នើសុំគម្រោងវិនិយោគនានា ក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- តាមដាន ត្រួតពិនិត្យ វិភាគ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- សម្របសម្រួលដោះស្រាយបញ្ហាប្រឈម និងផលវិបាកនានា នៃកិច្ចដំណើរការក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។



៤

## ជំពូកទី៣
## សមាសភាពរបស់ គ.ម.ហ.

**មាត្រា៣ .–**

**គ.ម.ហ.** មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | | អនុប្រធាន |
| ៣- | ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | ១រូប | អនុប្រធាន |
| ៤- | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | អនុប្រធាន |
| ៥- | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| ៦- | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ៧- | តំណាងក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| ៨- | តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| ៩- | តំណាងក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| ១០- | តំណាងក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ១១- | តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១រូប | សមាជិក |
| ១២- | តំណាងក្រសួងរ៉ែ និងថាមពល | ១រូប | សមាជិក |
| ១៣- | តំណាងក្រសួងបរិស្ថាន | ១រូប | សមាជិក |
| ១៤- | តំណាងក្រសួងធនធានទឹក និងឧតុនិយម | ១រូប | សមាជិក |
| ១៥- | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | សមាជិក |
| ១៦- | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ១រូប | សមាជិក |
| ១៧- | តំណាងក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ១៨- | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | សមាជិក |
| ១៩- | តំណាងក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ២០- | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| ២១- | តំណាងធនាគារជាតិនៃកម្ពុជា | ៣រូប | សមាជិក |
| ២២- | តំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | ១រូប | សមាជិក |
| ២៣- | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| ២៤- | តំណាងខុទ្ទកាល័យនាយករដ្ឋមន្ត្រី | ១រូប | សមាជិក |

២៥- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ១រូប សមាជិក

២៦- អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប សមាជិក

២៧- អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ១រូប សមាជិក

២៨- អគ្គលេខាធិការ នៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ១រូប សមាជិក

២៩- អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក

៣០- អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ១រូប សមាជិក

៣១- អគ្គនាយក នៃនិយ័តករសន្តិសុខសង្គម ១រូប សមាជិក

៣២- អគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា ១រូប សមាជិក

៣៣- អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច ១រូប សមាជិក

៣៤- អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម ១រូប សមាជិក

៣៥- អគ្គនាយក នៃនិយ័តករធានារ៉ាប់រងកម្ពុជា ១រូប សមាជិក

៣៦- អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ ១រូប សមាជិក

៣៧- អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ១រូប សមាជិកអចិន្ត្រៃយ៍។

**គ.ម.ហ.** អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័ន ឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ម.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ម.ហ.

**មាត្រា៤ .–**

**គ.ម.ហ.** ត្រូវជួបប្រជុំរៀងរាល់ ១ (មួយ) ឆ្នាំ ម្តង ឬតាមការចាំបាច់។

តាមការអញ្ជើញរបស់ប្រធាន, សមាជិក និងអនុប្រធាន **គ.ម.ហ.** ត្រូវចូលរួមប្រជុំ ឬចាត់តំណាងដែលមានសិទ្ធិសម្រេច ចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។

**មាត្រា៥ .–**

**គ.ម.ហ.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឥស្សរជនដែលមានបទពិសោធន៍ សមត្ថភាព និងជំនាញវិជ្ជាជីវៈចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំ **គ.ម.ហ.** តាមការចាំបាច់។

**មាត្រា៦ .–**

**គ.ម.ហ.** ត្រូវរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពការងារ និងលទ្ធផលនៃការវាយតម្លៃលើការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងបញ្ហាប្រឈមនានា ជូនប្រមុខរាជរដ្ឋាភិបាល។



៤

**មាត្រា៧ .-**

**គ.ម.ហ.** ត្រូវបង្កើតរដ្ឋបាលគ្រប់គ្រងពិសេស សម្រាប់ធានាដល់កិច្ចដំណើរការនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ប្រកបដោយប្រសិទ្ធភាព។ ការរៀបចំនិងការប្រព្រឹត្តទៅនៃរដ្ឋបាលគ្រប់គ្រងពិសេស ត្រូវកំណត់ដោយអនុក្រឹត្យ តាមការស្នើរបស់ប្រធាន **គ.ម.ហ.**។

**មាត្រា៨ .-**

**គ.ម.ហ.** ត្រូវបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារនានា តាមការចាំបាច់ សម្រាប់ធានាដល់កិច្ចដំណើរការនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ប្រកបដោយប្រសិទ្ធភាព។ ការរៀបចំនិងការប្រព្រឹត្តទៅនៃ អនុគណៈកម្មាធិការ ឬក្រុមការងារនានា ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ម.ហ.**។

**មាត្រា៩ .-**

**គ.ម.ហ.** មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការ សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** បំពេញមុខងារបន្ថែមជា អគ្គលេខាធិការដ្ឋាន **គ.ម.ហ.** ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

អគ្គលេខាធិការដ្ឋាន **គ.ម.ហ.** អាចមានទីប្រឹក្សាជាអ្នកជំនាញការជាតិ ឬអ្នកជំនាញការអន្តរជាតិមួយចំនួន ដែលមកពីដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ ស្ថាប័នអប់រំ និងវិស័យឯកជន សម្រាប់ជួយការងារតាមតម្រូវការចាំបាច់។

ទីប្រឹក្សាអគ្គលេខាធិការដ្ឋាន **គ.ម.ហ.** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ម.ហ.** តាមការស្នើរបស់អគ្គលេខាធិការ **គ.ម.ហ.**។

**មាត្រា១០ .-**

អគ្គលេខាធិការដ្ឋាន **គ.ហ.ម.** មានតួនាទី និងភារកិច្ច ដូចតទៅ៖

- រៀបចំសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការអភិវឌ្ឍមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- ស្នើឡើងនូវគោលនយោបាយលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ ក្នុងគោលបំណងទាក់ទាញវិនិយោគិនបរទេស ដាក់ជូន **គ.ម.ហ.** ពិនិត្យ និងសម្រេច
- រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់កិច្ចដំណើរការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា រួមទាំងការរៀបចំឱ្យមានច្រកចេញចូលតែមួយ រដ្ឋបាលមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា និងយន្តការដោះស្រាយវិវាទក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- រៀបចំបទប្បញ្ញត្តិ និងវិធានចាំបាច់នានា ដើម្បីពង្រឹងការអនុវត្តកិច្ចការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយមានកិច្ចសហការជាមួយនឹងក្រសួងស្ថាប័ន និងនិយ័តករពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់ជូន **គ.ម.ហ.** ដើម្បីដោះស្រាយរាល់បញ្ហាប្រឈម និងផលវិបាកនានា នៃកិច្ចដំណើរការក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា

- ពិនិត្យ និងផ្តល់យោបល់ជូន **គ.ម.ហ.** លើការស្នើសុំការអនុម័តផែនការមេ ឬការស្នើសុំកែប្រែផែនការមេនៃគម្រោង ដោយមានកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័ន និងនិយ័តករពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់ជូន **គ.ម.ហ.** លើការស្នើសុំការអនុម័តគម្រោងវិនិយោគនានា ក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ដោយមានកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័ន និងនិយ័តករពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ វិភាគ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ នៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- សហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍកិច្ចដំណើរការក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា
- រៀបចំកិច្ចប្រជុំរបស់ **គ.ម.ហ.** តាមការណែនាំរបស់ប្រធាន
- រៀបចំកំណត់ហេតុអង្គប្រជុំ និងធ្វើសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់ **គ.ម.ហ.** និងសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់រាជរដ្ឋាភិបាលលើការស្នើ និងអនុសាសន៍នានារបស់ **គ.ម.ហ.** ដល់សមាជិក **គ.ម.ហ.**
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូន **គ.ម.ហ.**
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ប្រធាន **គ.ម.ហ.**។

**មាត្រា១១ .—**

**គ.ម.ហ.** មានសិទ្ធិប្រើប្រាស់និមិត្តសញ្ញា និងត្រាដោយឡែក សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន **គ.ម.ហ.** មានសិទ្ធិប្រើប្រាស់និមិត្តសញ្ញា និងត្រារបស់ **គ.ម.ហ.** សម្រាប់ដំណើរការការងារប្រចាំថ្ងៃ។

## ជំពូកទី៥

## ប្រភពធនធានរបស់ គ.ម.ហ.

**មាត្រា១២ .—**

ប្រភពធនធានសម្រាប់ទ្រទ្រង់ដំណើរការរបស់ **គ.ម.ហ.** និងអគ្គលេខាធិការដ្ឋាន **គ.ម.ហ.** រួមមាន ប្រភពថវិការបស់ជាតិ ថវិកាដៃគូ និងប្រភពស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៣ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
## នៃអនុក្រឹត្យលេខ ៥១ អនក្រ.បក. ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥
## ស្តីពីនិមិត្តសញ្ញារបស់គណៈកម្មាធិការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា

**អត្ថន័យ៖**

និមិត្តសញ្ញារបស់គណៈកម្មាធិការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា មានអត្ថន័យដូចខាងក្រោម៖

- **រូបស្តេចហង្សពណ៌មាសមួយគូ៖** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា ដែល ជាអ្នកគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌។
- **រូបអគារ៖** តំណាងឱ្យហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានអភិវឌ្ឍក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ដោយគ្របដណ្តប់លើវិស័យស្នូលដែលជាសសរស្តម្ភរបស់មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជាគឺ វិស័យហិរញ្ញវត្ថុ វិស័យអប់រំ វិស័យសុខាភិបាល និងវិស័យទេសចរណ៍ពិសិដ្ឋ។
- **រូបទឹកសមុទ្រ និងដើមដូង៖** តំណាងឱ្យទេសភាពធម្មជាតិ និងសក្តានុពលក្នុងខេត្តព្រះសីហនុ ដែលមានលក្ខណៈអំណោយផលដល់វិស័យទេសចរណ៍ពិសិដ្ឋ និងពាណិជ្ជកម្ម សម្រាប់មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា។
- **រូបព្រះអាទិត្យរះ និងយន្តហោះ៖** តំណាងឱ្យចក្ខុវិស័យ ថាមពលវិជ្ជមាន និងសកម្មភាពរស់រវើកនៃដំណើរការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ប្រកបដោយចីរភាព ភាពរឹងមាំ និងនវានុវត្តន៍។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា "**គ.ម.ព.**" ដើម្បីពង្រឹង និងបង្កើន ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព នៃការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ លើការប្រមូល និងការកៀរគរចំណូលមិនមែនសារពើពន្ធ នៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## សមាសភាពនិងភារកិច្ច

**មាត្រា២ .-**

**គ.ម.ព.** មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ (មួយ) រូប | អនុប្រធាន |
| ៣. | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ) រូប | សមាជិក |
| ៤. | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១ (មួយ) រូប | សមាជិក |
| ៥. | រដ្ឋលេខាធិការទទួលបន្ទុកគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ នៃក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ | សមាជិក |
| ៦. | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១ (មួយ) រូប | សមាជិក |
| ៧. | អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. | អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩. | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ១០. | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១. | អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. | អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. | អគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤. | អគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥. | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ១៦. | អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. | អគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨. | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៩. | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២០. | អគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ២១. | អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ២២. | អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម | សមាជិក |
| ២៣. | អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| ២៤. | អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ម.៣.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣ .-**

**គ.ម.៣.** មានភារកិច្ច ដូចតទៅ៖

- តាមដានការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាព និងសូចនាករទាំងអស់ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលត្រូវបានកំណត់ដោយគោលនយោបាយ និងយុទ្ធសាស្ត្រជាធរមាន
- ជំរុញនិងផ្តល់ការណែនាំ ដល់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធ លើការអនុវត្តផែនការសកម្មភាព នៃការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេល ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រជាធរមាន
- រៀបចំ បូកសរុបរបាយការណ៍ និងវាយតម្លៃ លើវឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពការប្រមូលចំណូល និងការតឹងទារបំណុលមិនមែនសារពើពន្ធ ជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៤ .-**

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចាត់តាំងរដ្ឋលេខាធិការ មួយរូប ដើម្បីចូលរួមជា សមាជិក **គ.ម.៣.** ដែលត្រូវទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងបូកសរុបការប្រមូល ការកត់ត្រាការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុល នៅក្នុងក្របខណ្ឌ នៃសមត្ថកិច្ច របស់សាមីក្រសួង ស្ថាប័ន។

រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបូកសរុបរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុល មិនមែនសារពើពន្ធ របស់សាមីក្រសួង ស្ថាប័ន ដើម្បីផ្ញើជូន **គ.ម.៣.** ពិនិត្យ តាមដាន បូកសរុប វាយតម្លៃ និងស្នើសុំវិធានការពីប្រមុខរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់។

រដ្ឋលេខាធិការទទួលបន្ទុកគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ នៃសាមីក្រសួង ស្ថាប័ននីមួយៗ មានអង្គភាពហិរញ្ញវត្ថុ ដែលទទួលបន្ទុកកត់ត្រាការប្រមូលចំណូល រួមទាំងរដ្ឋទេយ្យករចំណូលនិងមន្ត្រីពាក់ព័ន្ធ ប្រចាំសាមី ក្រសួង ស្ថាប័ន ជាសេនាធិការ ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។



៤

**មាត្រា៥ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវមាន អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត មួយរូប ចូលរួមជាសមាជិក នៃ **គ.ម.ព.** ដែលត្រូវទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងបូកសរុបការប្រមូល ការកត់ត្រា ការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុល នៅក្នុងក្របខណ្ឌ នៃសមត្ថកិច្ចនៃរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន។

រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបូកសរុបរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមដែនសមត្ថកិច្ចភូមិសាស្ត្ររបស់ខ្លួន ដើម្បីផ្ញើជូន **គ.ម.ព.** ពិនិត្យ តាមដាន បូកសរុប វាយតម្លៃ និងស្នើសុំវិធានការពីប្រមុខរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់។

**មាត្រា៦ .-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើត "**គណៈកម្មការត្រួតពិនិត្យ តាមដាន វាយតម្លៃលើការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**" ដែលស្ថិតនៅក្នុងភូមិសាស្ត្ររបស់ខ្លួន ដើម្បីជាសេនាធិការ និងមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| ២. អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ១ (មួយ)រូប | អនុប្រធាន |
| ៣. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | អនុប្រធានប្រចាំការ |
| ៤. អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | សមាជិក |
| ៥. ប្រធានមន្ទីរ អង្គភាពជំនាញ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អភិបាលរាជធានី ខេត្តសាមី។

**មាត្រា៧ .-**

គណៈកម្មការត្រួតពិនិត្យ តាមដាន វាយតម្លៃលើការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបំពេញតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ត្រួតពិនិត្យ តាមដាន និងបូកសរុបការប្រមូល ការកត់ត្រា ការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុលមិនមែនសារពើពន្ធ នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន
- បូកសរុបរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុលមិនមែនសារពើពន្ធ របស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី ដើម្បីផ្ញើជូន **គ.ម.ព.** ពិនិត្យ តាមដាន បូកសរុប វាយតម្លៃ និងស្នើសុំវិធានការពីប្រមុខរាជរដ្ឋាភិបាល
- បំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានគណៈកម្មការ។

**មាត្រា៨ .-**

គណៈកម្មការត្រួតពិនិត្យ តាមដាន វាយតម្លៃលើការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានតាមការប្រគល់សិទ្ធិ។



ស

ក្នុងករណីចាំបាច់គណៈកម្មការ អាចអញ្ជើញភាគីពាក់ព័ន្ធទាំងផ្នែកឯកជន និងសាធារណៈ ព្រមទាំងសង្គមស៊ីវិលចូលរួមពិគ្រោះយោបល់រាល់បញ្ហាទាក់ទងនឹងក្របខណ្ឌនៃការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាលសាមីនីមួយៗ។

របៀបរបបបំពេញការងារដាក់ស្តែងរបស់គណៈកម្មការ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត នីមួយៗ។

## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៩ .-**

សមាសភាពនៃ **គ.ម.ព.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.ម.ព.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

ប្រធាន **គ.ម.ព.** អាចអញ្ជើញមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធផ្សេងទៀត ចូលរួមពិគ្រោះយោបល់តាមការចាំបាច់។

**គ.ម.ព.** មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

**គ.ម.ព.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១០ .-**

**គ.ម.ព.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ម.ព.** ដោយមានជំនួយពីអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានភារកិច្ច ដូចតទៅ៖

- រៀបចំ និងសម្របសម្រួលការងារប្រជុំរបស់ **គ.ម.ព.** តាមការណែនាំរបស់ប្រធាន **គ.ម.ព.**
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រជាធរមាន
- ដឹកនាំ និងសម្របសម្រួល ជាមួយដៃគូអភិវឌ្ឍន៍ លើការងារស្រាវជ្រាវពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ
- រៀបចំ ពិនិត្យ តាមដាន សម្របសម្រួល និងបូកសរុបរបាយការណ៍វឌ្ឍនភាព ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកៀរគរចំណូលនិងតឹងទារបំណុលមិនមែនសារពើពន្ធជូន **គ.ម.ព.**
- រៀបចំអនុសាសន៍ជូន **គ.ម.ព.** ស្តីពីការជំរុញការអនុវត្តផែនការសកម្មភាពកៀរគរចំណូល និងតឹងទារបំណុលមិនមែនសារពើពន្ធឱ្យស្របតាមសូចនាករដែលបានកំណត់
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាន **គ.ម.ព.** ។



៥

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

អនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ស្ដីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៨៤ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយសហមេត្រី**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **សេនា** ជូនវរសេនីយ៍ឯក PARK, Suman នាយការិយាល័យអនុព័ន្ធយោធា នៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទកន្លងមក។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៥
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨៥ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងមន្ត្រីរាជការនៅអគ្គនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម៖

១- លោក **ទី ទ៉ា** អត្តលេខ ១៧៤០២០០៤១៨ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយករង

| | |
|---|---|
| ២- លោកស្រី **លឹម ភិត្យា** | អត្តលេខ ២៨៣១២០០២៤០ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយករង |
| ៣- លោក **អ៊ី សុខុន** | អត្តលេខ ១៨៥១៤០០២៩១ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយករង |
| ៤- លោក **រាត់ សុខជា** | អត្តលេខ ១៧០១២០០១០២ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុធនាគារ និងវិនិយោគ |
| ៥- លោក **ហាម សេងតា** | អត្តលេខ ១៧២០៨០០០៧០ ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋានឧស្សាហកម្មរ៉ែ និងថាមពល |
| ៦- លោក **ខឹង ពេជ្រមុនី** | អត្តលេខ ១៩៥១២០០៤៤៤ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋានពាណិជ្ជកម្មនិងទេសចរណ៍ |
| ៧- លោក **យឹត ស៊ុនណារាឧត្តម** | អត្តលេខ ១៨៧១២០០៣១៧ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋានផែនការនិងអភិវឌ្ឍន៍។ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង ប្រគល់ភារកិច្ច និងសម្រួលភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម(ប.ស.ស)
- បានឃើញអនុក្រឹត្យលេខ ៤៨៩ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ



៥

**សម្រេច**

**មាត្រា ១ .–**

ត្រូវបានតែងតាំង ប្រគល់ភារកិច្ច និងសម្រួលភារកិច្ចមន្ត្រីរាជការចំនួន ០៣ រូប របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម៖

១-លោក **ម៉ាញ ណារិទ្ធ** អត្តលេខ ១៨៥២១០០៥២១ ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធាននាយកដ្ឋានពេទ្យការងារ ជំនួសលោក **ឡេង តុង** ដែលត្រូវទទួលភារកិច្ចថ្មី

២-លោក **ឌីម ឧត្តម** អត្តលេខ ១៩២០៨០០២៣៨ ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ ជំនួសលោក **ខេម ប៊ុនឈាន** ដែលត្រូវទទួលភារកិច្ចថ្មី

៣-លោក **មាន ណារិមន្ត** អត្តលេខ ១៩២១២០០២៧៦ ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល សម្រួលភារកិច្ចពីប្រធានផ្នែកផែនការ និងសហប្រតិបត្តិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ទៅជាប្រធាននាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាលនៃបេឡាជាតិសន្តិសុខសង្គម ជំនួសលោក **ទុត ប៉ូឡារី** ដែលបានលាឈប់។

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥ រោច ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៨៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការដូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនបុគ្គលិកអប់រំ ចំនួន ៩០រូប នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ឈីវ គឹមសាយ | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ២- | លោកស្រី | ឈួន ណារី | អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៣- | លោក | សួង ណូយ | អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៤- | លោកស្រី | អ៊ុំ សំអឿន | អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |



៥

| | | | |
|---|---|---|---|
| ៥- | លោក | សេង ខេមាលា | អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៦- | លោកស្រី | សៀន រក្សា | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៧- | លោក | តេង សុជាតិ | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៨- | លោក | ណុប គន្ធា | នាយករងវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ៩- | លោក | ព្រិញ ចាន់ហ្សូរ | នាយករងវិទ្យាល័យអន្តេវាសិកដ្ឋាន ក្រុងបានលុង |
| ១០- | លោក | គឹម ជីលីន | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ១១- | លោក | ឈុន សុគន្ធា | គណៈគ្រប់គ្រងអនុវិទ្យាល័យ ប៊ូ ថង ទេសអន្លង ក្រុងបានលុង |
| ១២- | លោក | ឋោង តៃឈាង | នាយកអនុវិទ្យាល័យកាចាញ ក្រុងបានលុង |
| ១៣- | លោកស្រី | មៀច ច័ន្ទឡាយហេង | នាយិកាវិទ្យាល័យបរកែវ ស្រុកបរកែវ |
| ១៤- | លោក | ម៉ម បាសាក់ | នាយកវិទ្យាល័យអណ្តូងមាស ស្រុកអណ្តូងមាស |
| ១៥- | លោក | ង៉ែត សុភេន | នាយកអនុវិទ្យាល័យត្រពាំងច្រេស ស្រុកកូនមុំ |
| ១៦- | លោក | អ៊ួង សុខរដ្ឋ | នាយកអនុវិទ្យាល័យវើនសៃ ស្រុកវើនសៃ |
| ១៧- | លោក | នៅ សំបូរ | នាយកអនុវិទ្យាល័យវើនសៃ ស្រុកវើនសៃ។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- | លោក | តាន់ ពុទ្ធីរ៉ា | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ២- | លោក | ចាប ពិសិដ្ឋ | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៣- | លោកស្រី | ថាន ចរិយា | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៤- | លោកស្រី | សុំ ច័ន្ទថាវ៉ន | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៥- | លោក | ហុង ចំរើន | គ្រូបង្រៀនវិទ្យាល័យលំផាត់ ស្រុកលំផាត់ |
| ៦- | លោក | កឿក គឹមសាន | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ៧- | លោក | មេង សុគន្ធ | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ៨- | លោក | ឈួន វិឈាន | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ៩- | លោកស្រី | ហុង សុម៉ាលី | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ១០- | លោក | ផុន សុភ័ក្រ | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ១១- | លោកស្រី | ឃឿប ថាវរី | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ១២- | លោកស្រី | កាន់ វិជ្ជនី | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ១៣- | លោក | លើយ សិទ្ធិ | គ្រូបង្រៀនវិទ្យាល័យសម្តេចឳ សម្តេចម៉ែ ក្រុងបានលុង |
| ១៤- | លោកស្រី | កឿន សុភា | គ្រូបង្រៀនវិទ្យាល័យអន្តេវាសិកដ្ឋាន ក្រុងបានលុង |

| | | | |
|---|---|---|---|
| ១៥- | លោក | អៀម អឿន | នាយកវិទ្យាល័យលំផាត់ ស្រុកលំផាត់ |
| ១៦- | លោក | ឡាច ហោ | គ្រូបង្រៀនវិទ្យាល័យសាមុគ្រសេដា ស្រុកលំផាត់ |
| ១៧- | លោក | ថៃ សុផា | នាយកអនុវិទ្យាល័យលុងឃុង ស្រុកបរកែវ |
| ១៨- | លោក | លឹម សំ | គ្រូបង្រៀនវិទ្យាល័យសោមធំ ស្រុកអូរយ៉ាដាវ |
| ១៩- | លោក | ច្រឹក ប៊ុនថេត | នាយកអនុវិទ្យាល័យប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ |
| ២០- | លោក | ម៉ក់ ធារី | នាយកអនុវិទ្យាល័យស្រែអង្គ្រង ស្រុកកូនមុំ |
| ២១- | លោក | ថា សៃ | គ្រូបង្រៀនអនុវិទ្យាល័យស្រែអង្គ្រង ស្រុកកូនមុំ |
| ២២- | លោក | លឹម ធីណា | នាយកអនុវិទ្យាល័យ ប៊ូ ថង ខាំ កៀន យ៉ាក់ប៉ូយ ស្រុកអូរជុំ។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១- | លោក | កែវ សារឿន | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ២- | លោកស្រី | អ៊ុច សុម៉ាលី | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៣- | លោកស្រី | សិទ្ធិ សុម៉ាលី | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៤- | លោក | កឿក សុគន្ធ | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៥- | លោក | ហ៊ី ស៊ុនធី | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៦- | លោក | ឡេង ប៊ុនធឿន | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៧- | លោក | លឿង ធីណា | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៨- | លោកស្រី | ប៊ុន សុខាន់ | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ៩- | លោកស្រី | ហ៊ួយ ថារី | គ្រូបង្រៀនវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ក្រុងបានលុង |
| ១០- | លោកស្រី | លឿង សារ័ត្ន | នាយិការងវិទ្យាល័យអន្តេវាសិកដ្ឋាន ក្រុងបានលុង |
| ១១- | លោកស្រី | គឹម ធីតា | គ្រូបង្រៀនវិទ្យាល័យអន្តេវាសិកដ្ឋាន ក្រុងបានលុង |
